ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែកញ្ញា ឆ្នាំ២០១៥

នៅក្នុងខែកញ្ញា ឆ្នាំ២០១៥នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ:

**១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន៖**

-បានទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី

-សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ទទួលសារតាំងពីឯកឧត្តម Naveen Srivasiava ឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសាធារណរដ្ឋឥណ្ឌា ប្រចាំព្រះរាជាណាចក្រកម្ពុជា

-សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ទទួលសារតាំងពីឯកឧត្តម Aziz Ponary Ml ima ឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសាធារណរដ្ឋឯកភាពតង់ហ្សានី ប្រចាំព្រះរាជាណាចក្រកម្ពុជា

-អនុញ្ញាតឲ្យឯកឧត្តម Mohammad Hamid Ansari អនុប្រធានាធិបតី នៃសាធារណរដ្ឋឥណ្ឌា ចូលរួមសម្តែងការគួរសម និងសវនាការ ក្នុងឱកាសដែលឯកឧត្តមដឹកនាំគណៈប្រតិភូជាន់ខ្ពស់នៃសាធារណរដ្ឋឥណ្ឌា មកបំពេញទស្សនកិច្ចផ្លូវការ នៅព្រះរាជាណាចក្រកម្ពុជា

-អនុញ្ញាតឲ្យឯកឧត្តម Arken Imirbaki អនុប្រធានសភាប្រជាជនចិនតំណាងទូទាំងប្រទេសនីតិកាលទី១២ និងសមាជិកគណៈប្រតិភូ ចូលរួមសម្តែងការគួរសម និងសវនាការ

-អញ្ជើញចូលរួមពិធីបុណ្យគម្រប់ខួប១០០ថ្ងៃ និងដង្ហែអដ្ឋិធាតុ**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ឆ្ពោះទៅស្រុកកំចាយមារ ខេត្តព្រៃវែង

-អញ្ជើញប្រារព្ធពិធីបង្សុកូល ឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធបុព្វការីជន



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum sarith@camnet.com.kh

យុទ្ធជន យុទ្ធនារី ដែលបានពលីជីវិតក្នុងសម័យតស៊ូរំដោះជាតិមាតុភូមិ នាចេតិយ៍ពាម អំពិល នៅភូមិកន្ទែងជ្រៅ ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង

-អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **ឆាយ គីម** អគ្គសវនកម្មរង នៃអាជ្ញាធរសវនកម្មជាតិ ដែលបានទទួលមរណភាពកាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៥

-អញ្ជើញចូលរួមរំលែកទុក្ខក្រុមគ្រួសារសពឯកឧត្តម **រស់ ស្រេង** អតីតសមាជិកព្រឹទ្ធសភា និងជាទីប្រឹក្សាផ្ទាល់សម្តេចវិបុលសេនាភក្តី សាយ ឈុំ ដែលបានទទួលមរណភាពកាលពីយប់ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥

-អញ្ជើញចុះសួរសុខទុក្ខ និងលើកទឹកចិត្តកម្មករ កម្មការនី នៅការដ្ឋានសាងសង់ស្ពានវង្វង់មូល ជ្រោយចង្វារត្រើយខាងកើត

-ចុះហត្ថលេខាលើព្រះរាជក្រឹត្យចំនួន៨៧ច្បាប់

-ទទួលព្រះរាជប្រទានសិទ្ធចំនួន៨៧ច្បាប់ សំណើពីរាជរដ្ឋាភិបាលចំនួន៨៥ច្បាប់ និងសំណើរបស់សម្តេចប្រមុខរដ្ឋស្តីទីចំនួន០២ច្បាប់

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៣ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១១៧ច្បាប់ ។

**១.២.ឯកឧត្តម នៃ ប៉េណា អនុប្រធានទី១ព្រឹទ្ធសភា បាន** :

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភា

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០១លើក

-អញ្ជើញចូលរួមពិធីដង្ហែអដ្ឋិធាតុ**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ឆ្ពោះទៅស្រុកកំចាយមារ ខេត្តព្រៃវែង

-អញ្ជើញចុះសំណេះសំណាលជាមួយប្រជាពលរដ្ឋនៅឃុំតានីស្រុកអង្គរជ័យ និងនៅទីរួមខេត្តកំពត

-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីជប់លៀងអបអរសាទរខួបលើកទី៧០ នៃថ្ងៃបុណ្យជាតិរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៣៩ច្បាប់ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភាបាន** :

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០១លើក

-អនុញ្ញាតឲ្យលោកសាស្ត្រាចារ្យ Heinrich Grosse-Sender អតីតអគ្គលេខាធិការសភានៃរដ្ឋន័តវ៉ែនហ្វាសិន នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ

-អញ្ជើញចូលរួមពិធីបុណ្យខួបគម្រប់១០០ថ្ងៃ និងដង្ហែអដ្ឋិធាតុ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ធ្លោះទៅស្រុកកំចាយមារ ខេត្តព្រៃវែង

-អញ្ជើញដឹកនាំសមាជិកព្រឹទ្ធសភាគោរពវិញ្ញាណក្ខន្ធ និងបំពាក់គ្រឿងឥស្សរិយយសជាតូបការដោកិច្ចបច្ឆាមរណៈ និងប្រគល់ភ្លើងបូជាសពឯកឧត្តម **រស់ ស្រេង** អតីតសមាជិកព្រឹទ្ធសភា នៅវត្តចំពុះក្អែក

-អញ្ជើញជួបសំណេះសំណាល និងចែកអំណោយជូនសមាជិកក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ នៅឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៩១ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២២ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០១លើកដើម្បី** ៖

១.ពិនិត្យ និងសម្រេចលើសេចក្តីស្នើច្បាប់ ស្តីពីវិសោធនកម្មមាត្រា២១ នៃច្បាប់ស្តីពីលក្ខន្តិកៈសមាជិកព្រឹទ្ធសភា

២.ស្តាប់របាយការណ៍របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អំពីករណីពាក់ព័ន្ធនឹងផលប្រយោជន៍របស់ ឈ្មោះ **ហុង សុខហួរ** សមាជិកព្រឹទ្ធសភា មណ្ឌលភូមិភាគទី៤ ។

**៣. គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែកញ្ញានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម :

**៣.១. មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងបានចំនួន១២ករណី ផ្ញើលិខិតអន្តរាគមន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយបានចំនួន០៩ករណី ទទួលលិខិតឆ្លើយតបពីអាជ្ញាធរ

ជាតិដោះស្រាយទំនាស់ដីធ្លីចំនួន០១ករណី សាលាខេត្តត្បូងឃ្មុំចំនួន០១ករណី និង សាលាខេត្តកំពង់ឆ្នាំងចំនួន០១ករណី បានឆ្លើយតបទៅម្ចាស់បណ្តឹងបានចំនួន០៣ករណី ទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធបានចំនួន២៣ករណី

-ចុះផ្សព្វផ្សាយអំពីបទបញ្ញាតិវិធីចុះឈ្មោះបោះឆ្នោត ជូនក្រុមប្រឹក្សាសង្កាត់ ស្មៀន ក្រុមយុវជន នៅក្រុងប៉ោយប៉ែតសរុបចំនួន៧០នាក់

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ ប្រជុំដើម្បីពិគ្រោះយោបល់ និង ប្រមូលព័ត៌មានអំពីលទ្ធផល ក្រោយការធ្វើវេទិកាភូមិភាគកន្លងមករបស់ស្រុកពារាំង ស្រុកស៊ីធរកណ្តាល ស្រុកកំពង់ត្របែក និងស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង

-សមាជិកព្រឹទ្ធសភាប្រចាំភូមិភាគ៩ ប្រជុំដើម្បីឆ្លងរបាយការណ៍ស្រាវជ្រាវ ប្រមូល ព័ត៌មាននៅក្នុងខេត្តតាកែវ និងពិភាក្សាជុំវិញគម្រោងរៀបចំវេទិកាថ្នាក់ខេត្ត នៅ ខេត្តតាកែវ

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ប្រជុំដើម្បីឆ្លងរបាយការណ៍លទ្ធផល ការងារនៃការឈ្វេងយល់អំពីវឌ្ឍនភាពរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ក្រោយវគ្គបណ្តុះ បណ្តាលជំនាញការធ្វើផែនការវិនិយោគនៅខេត្តប៉ៃលិន និងខេត្តសៀមរាប និងពិភាក្សា លើគម្រោងសិក្សាស្រាវជ្រាវប្រមូលព័ត៌មានបឋម មុនឈានទៅរៀបចំវេទិកា នៅខេត្ត បាត់ដំបង

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ប្រជុំដើម្បីពិនិត្យឆ្លងរបាយការណ៍បូក សរុបលទ្ធផលរៀបចំវេទិកាថ្នាក់ខេត្តស្តីពីការបង្កើនសមត្ថភាព និងការអភិវឌ្ឍមូលដ្ឋាន របស់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅខេត្តមណ្ឌលគិរី

-ប្រជុំពិភាក្សាអំពីការរៀបចំគោលការណ៍ចុះមូលដ្ឋានរបស់ក្រុមសមាជិកព្រឹទ្ធសភា ប្រចាំភូមិភាគទី៦ ដើម្បីពិគ្រោះយោបល់ និងផ្តល់ព័ត៌មានស្តីពីលទ្ធផលក្រោយការធ្វើ វេទិកាភូមិភាគជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្រុក ខេត្ត ចំនួន០២លើកកន្លងមក

-ប្រជុំពិភាក្សាការងារជាមួយលោក **ដារ៉ា រិទ្ធគីមយ៉ាត** នាយកវិទ្យាស្ថានសភា កម្ពុជា ស្តីពីគម្រោងបេសកកម្មក្រៅប្រទេសរបស់គណៈកម្មការទី១

-ក្រុមសភាជាតិទទួលបន្ទុកកិច្ចការអន្តរសភាកម្ពុជា-ឡាវ-វៀតណាម ប្រជុំស្តីពី វឌ្ឍនភាពនៃការអនុវត្តគម្រោងផែនការអភិវឌ្ឍតំបន់ត្រីកោណ ដើម្បីត្រៀមចូលរួម

សន្និសីទលើកទី៦ នៅខេត្តចំប៉ាសាក់ ប្រទេសឡាវ

-ចូលរួមក្នុងពិធីធ្វើបាឋកថាសាធារណៈស្តីពីចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការឡាវ-កម្ពុជា ដោយឯកឧត្តមឯកអគ្គរដ្ឋទូតឡាវប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

-ចូលរួមសិក្ខាសាលាស្តីពី " បច្ចេកវិទ្យាព័ត៌មាន ការទំនាក់ទំនង និងតម្លាភាពសភា " ដែលរៀបចំដោយអគ្គលេខាធិការដ្ឋានរដ្ឋសភា និងព្រឹទ្ធសភា សហការជាមួយលេខាធិការដ្ឋាន នៃសមាគមសភាប្រើប្រាស់ភាសាបារាំង(APF) " ប្រព័ន្ធសន្តិសុខដើម្បីធានាចំពោះអាយុជីវិត និងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ " រៀបចំដោយក្រសួងមហាផ្ទៃ និងក្រុមហ៊ុន E-Security Services Co.ltd.japan និងសិក្ខាសាលាផ្សព្វផ្សាយសេចក្តីសង្ខេបគោលនយោបាយស្តីពី " ការចរចារអាកាសធាតុ ការត្រៀមលក្ខណៈសម្រាប់សន្និសីទនៃភាគីជាសមាជិកអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុលើកទី២១"

-ចូលរួមស្តាប់បទបង្ហាញរបស់វិទ្យាស្ថានសភាកម្ពុជា(PIC)ស្តីពី " ការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ"

-ចូលរួមមហាសន្និបាតតំណាងសមាគមអតីតយុទ្ធជនកម្ពុជាទូទាំងប្រទេសលើកទី២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-ជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយគណៈប្រតិភូស្ថានទូតឡាវប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងគណៈប្រតិភូខេត្តយ៉ាឡាយ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម

-ជួបពិភាក្សាការងារជាមួយមន្ត្រីជំនាញនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីដំណើរការរៀបនៃសេចក្តីព្រាងច្បាប់ស្តីពីសហជីព

-អនុញ្ញាតឲ្យគណៈប្រតិភូជប៉ុន ដឹកនាំដោយលោក Masanao General Manager Global Business Support and Promotion Development ចូលជួបពិភាក្សាការងារ ដើម្បីរកឱកាសបណ្តាក់ទុនវិនិយោគរួមគ្នានៅកម្ពុជា

សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេសចំនួន១៤៦លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ - សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោល

នយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗ លើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៦២លើក។

**៣.២. មុខងារព័ត៌មាន**

-អញ្ជើញចុះបេសកកម្មដើម្បីឈ្វេងយល់អំពីការអនុវត្តសិទ្ធិមនុស្ស និងដោះស្រាយពាក្យបណ្ដឹងរបស់ប្រជាពលរដ្ឋនៅថ្នាក់ក្រោមជាតិ នៅខេត្តកំពង់ស្ពឺ ខេត្តកំពត និងខេត្តព្រះសីហនុ

-អញ្ជើញចុះទៅសិក្សាឈ្វេងយល់អំពីការអភិវឌ្ឍទីតាំងស្ថានីយ និងទំនប់វារីអគ្គិសនីសំខាន់ៗនៅខេត្តកោះកុង និងខេត្តពោធិ៍សាត់ និងជួបសំណេះសំណាល និងដោះស្រាយសំណូមពររបស់ប្រជាពលរដ្ឋ ក្នុងឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់

-អញ្ជើញចុះតាមដានលទ្ធផល និងស្វែងយល់ពីវឌ្ឍនភាពនៅមូលដ្ឋានក្រោយពីបើកវេទិកាថ្នាក់ខេត្ត-ស្រុកកន្លងមក នៅខេត្តសៀមរាប និងខេត្តព្រៃវែង។

**៤. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-លោកជំទាវ **ពុំ ស៊ីចាន់** ឯកឧត្តម **ឈិត គឹមយាត** និងឯកឧត្តម **សោ ចាន់ដេត** អញ្ជើញទៅចូលរួមមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី៣៦ នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី

-លោកជំទាវ **ឈូក ឈឹម** អញ្ជើញចូលរួមសន្និសីទតំបន់អាស៊ីប៉ាស៊ីហ្វិកលើកទី៧ ស្ដីពីការពង្រឹងសាមគ្គីភាពជាមួយប្រទេសគូប៉ា នៅសាធារណរដ្ឋសង្គមនិយមវៀតណាម

-ឯកឧត្តម **ឈិត គឹមយាត** អញ្ជើញចូលរួមកិច្ចប្រជុំកំពូលសហគ្រិនពាណិជ្ជកម្មលើកទី២ អាស៊ាន-ចិន ឆ្នាំ២០១៥ នៅទីក្រុង Nanning ខេត្ត Guangxi នៃសាធារណរដ្ឋប្រជាមានិតចិន ។

រាជធានីភ្នំពេញ,ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៥

ជ.ប្រធានព្រឹទ្ធសភា

អនុប្រធានទី២

ទេព ងន

ចម្លងជូន:
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)